# ទម្លាប់ចាប់ត្រីធ្វើបុណ្យឡើងមាឃនៅភូមិបង្កោងនៃតំបន់អង្គរ

ភូមិបង្កោង ស្ថិតនៅក្នុងឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានចម្ងាយប្រហែលជាង១០គីឡូម៉ែត្រនៃភាគខាងកើតទីរួមខេត្ត និងប្រហែលជិត១០គីឡូម៉ែត្រខាងជើង ប្រាសាទបាគង (រូបលេខ១)។ គេដឹងថានៅក្នុងភូមិបង្កោងមានត្រពាំងបុរាណធំមួយហៅថា "ត្រពាំងបឹង" ដែលជាប្រភពត្រីយ៉ាងសម្បូរសម្រាប់អ្នកស្រុកនេសាទចាប់រួមគ្នាមួយឆ្នាំម្តង ដូចឃើញល្បីល្បាញលើប្រព័ន្ធផ្សព្វផ្សាយសង្គមសព្វថ្ងៃ។ ប៉ុន្តែការពិត ការចាប់ត្រីរួមគ្នាក្នុងភូមិនេះធ្វើឡើងរាល់ឆ្នាំនៅក្នុងអំឡុងដើមខែមាឃ ដ្បិតតាមទម្លាប់ គឺត្រីមួយភាគដែលអ្នកភូមិចាប់បានពីត្រពាំងបឹង រំលែកទុកសម្រាប់ផ្គត់ផ្គង់ធ្វើម្ហូបក្នុងពិធីនៅថ្ងៃបន្ទាប់ហៅថា"បុណ្យឡើងមាឃ" ឬ "ឆាន់ឡើងមាឃ"។ ពិធីនេះ គឺជាទំនៀមប្រចាំភូមិតែងប្រារព្ធក្រោយប្រមូលផលស្រូវរួចរាល់ ហើយដែលភ្នែកអ្នកផងពីចម្ងាយមើលឃើញភាពគគ្រឹកគគ្រេង "ការចាប់ត្រី" តែអ្នកស្រាវជ្រាវភាគច្រើនយល់ថា ជាទំនៀមយ៉ាងសំខាន់ពាក់ព័ន្ធនឹងពិធីនៅចុងបញ្ចប់នៃរដូវធ្វើស្រែ ឬ "វដ្តស្រូវ"។




រូបលេខ១ ទីតាំងភូមិសាស្ត្រត្រពាំងបឹងក្នុងភូមិបង្កោង (ប្រភព៖ ព្រះនគរ, ២០២១)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជាការពិត ជារៀងរាល់ឆ្នាំនៅដើមខ្នើតក្នុងខែមាឃ អ្នកស្រុករស់នៅតំបន់អង្គរតែងប្រារព្ធពិធី "ឡើងមាឃ" ពុំដែលខកខានឡើយ។ អ្នកភូមិភាគច្រើនប្រារព្ធពិធីនៅថ្ងៃ៣កើត ហើយអ្នកខ្លះហៅពិធីនេះថា "៣កើតមាឃធំ" ក៏មាន។[1] ទីតាំងដែលគេតែងប្រារព្ធពិធីឡើងមាឃ ឬ៣កើតមាឃធំ គឺពុំដែលឃើញធ្វើនៅតាមវត្តដូចបុណ្យដទៃឡើយ ពោលគឺគេច្រើនធ្វើនៅសាលាបុណ្យ ឬសាលាសំណាក់ក្នុងភូមិ នៅក្នុងបរិវេណប្រាសាទ នៅខ្ទមអ្នកតាក្នុងវត្ត ឬនៅតាមទីទួលអ្នកតាណាមួយក្នុងភូមិ ហើយគេក៏ហៅពិធីនេះម្យ៉ាងទៀតដែរថា "ឡើងអ្នកតា"។ ភូមិមួយចំនួននៅក្នុងតំបន់អង្គរដែលគេធ្លាប់សម្គាល់ឃើញប្រារព្ធពិធីឡើងមាឃ ឬឡើងអ្នកតា គឺមានទាំងភូមិនៅតំបន់ខាងលើ(ខិតទៅជិតភ្នំគូលែន) តំបន់កណ្ដាល (ជុំវិញរមណីយដ្ឋានអង្គរ) និងតំបន់ខិតទៅក្បែរទន្លេសាប។ ប៉ុន្តែសព្វថ្ងៃគេមើលឃើញថាភូមិបង្កោង គឺជាភូមិមួយដែលប្រារព្ធពិធីឡើងមាឃយ៉ាងគគ្រឹកគគ្រេងជាងភូមិដទៃ ជាពិសេសគឺការចុះចាប់ត្រីរួមគ្នានៅត្រពាំងបឹង។

ចំពោះពិធីឡើងមាឃនៅភូមិបង្កោង ពុំកំណត់យកថ្ងៃជាក់លាក់ "៣កើតខែមាឃ" ដូចភូមិដទៃទេ ដ្បិតមានហេតុផលខ្លះបញ្ជាក់ថាអាស្រ័យលើការមូលមាត់ក្នុងភូមិ និងអាស្រ័យលើទឹកត្រពាំងស្រកអាចចុះចាប់ត្រីបានឬអត់។ ឆ្នាំខ្លះគេប្រារព្ធនៅថ្ងៃ៣កើត ខែមាឃ ហើយឆ្នាំខ្លះក្រោយថ្ងៃ៣កើត តែក៏មិនហួសខែមាឃឬឆ្លងចូលខែផល្គុនឡើយ។ តាមទម្លាប់អ្នកភូមិ គឺនៅមុនថ្ងៃប្រារព្ធពិធីគេតែងងើបពីព្រលឹមទៅជួបជុំគ្នានៅត្រពាំងបឹង ដើម្បីចុះចាប់ត្រីធ្វើម្ហូប ជាពិសេសធ្វើសម្ងំបញ្ចុក និងប្រគេនព្រះសង្ឃក្នុងថ្ងៃបន្ទាប់។ ត្រពាំងនេះមានទំហំប្រហែល១គីឡូម៉ែត្របួនជ្រុង(រូបលេខ២) ហើយគេទុកជាសម្បត្តិរួមរបស់ស្រុកភូមិ ដែលគេពុំដែលហ៊ានល្មើសទំនៀមចុះចាប់ត្រីមុនថ្ងៃកំណត់ឡើយ។[2] បំរាមនេះគេច្រើនដាក់កំហិតពីរវាងខែកត្តិក ដោយដាក់វេនយាមប្រចាំទាំងថ្ងៃទាំងយប់។ ការចាប់ត្រីក្នុងត្រពាំងនោះសោត គេអនុញ្ញាតឱ្យប្រើតែឧបករណ៍បុរាណរួមមាន សំណាញ់ មង អង្រុត និងឈ្នាងជាដើម (រូបលេខ៣)។ កម្មវិធីចុះចាប់ត្រីនេះ គឺចាប់ផ្ដើមមុនម៉ោង៧ព្រឹក (ចប់ម៉ោង១ ឬ២រសៀល) ដោយមានមេភូមិអុជកាំជ្រួចជាសញ្ញាអនុញ្ញាត។ រីឯអ្នក

[1] អាំង ជូលាន ២០១២-២០១៣: ៤៣-៤៨

[2] ខៀវ ច័ន្ទ ២០១៣-២០១៤: ៣៨-៤៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដែលអាចចុះចាប់ត្រីត្រពាំងក្នុងវេលានោះ គឺបានតែអ្នកភូមិបង្កោង និងអ្នកធ្លាប់មានផ្ទះកំណើតរស់នៅក្នុងភូមិបង្កោង តែប្ដូរទីលំនៅទៅរស់នៅភូមិផ្សេងប៉ុណ្ណោះ។

សូមបញ្ជាក់ថា នៅត្រពាំងបឹងនេះមានអ្នកតាបួន គឺអ្នកតាដេកផ្ងារ អ្នកតាបឹងឬអ្នកតាប្រសិទ្ធផ្ទ អ្នកតាសុខ និងអ្នកតាស្រុន។ ចំណែកឯនៅក្នុងភូមិ មានអ្នកតាច័នស្ថិតនៅក្រោមដើមច័នធំមួយ (រូបលេខ២៤) ដែលគេតែងថ្វាយដង្វាយផ្សេងៗក្នុងថ្ងៃធ្វើបុណ្យ។ ប៉ុន្តែយ៉ាងណាក្ដី ចំពោះអ្នកតាដេកផ្ងារ គេមើលឃើញជាក់ស្ដែងថាស្ថិតនៅក្នុងត្រពាំងហើយគឺជាថ្មគោលបុរាណរាងបួនជ្រុង មានឆ្លាក់ព្រះពុទ្ធជុំវិញ។ បើតាមអ្នកខ្លះអះអាងគឺកាលពីមុនមានថ្មគោលពីរ ប៉ុន្តែថ្មមួយទៀតគេលួចបាត់ទៅ ហើយថ្មដែលនៅសល់នេះគេទើបនឹងលើកបញ្ឈរ (រូបលេខ២៥)។



រូបលេខ២២ បរិវេណត្រពាំងបឹងមើលពីលើ



រូបលេខ២៣ ទិដ្ឋភាពចាប់ត្រីនៅត្រពាំងបឹង



រូបលេខ២៤ ខ្ទមអ្នកតាច័ននៅក្នុងភូមិ



រូបលេខ២៥ អ្នកតាដេកផ្ងារ (ថ្មគោលឆ្លាក់រូបព្រះពុទ្ធ)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដោយឡែក ផលត្រីដែលអ្នកភូមិរកបានពីត្រពាំងបឹងក្នុងមួយថ្ងៃនេះ គឺជាចំណែករៀងៗខ្លួនសម្រាប់យកទៅធ្វើសម្ងំនំបញ្ចុក ឬចម្អិនហូបភ្ជាមក្បែរមាត់ត្រពាំងៗ ចំណែកឯត្រីដែលហ៊ុមចាប់នៅក្នុងសម្រាស់រួមគ្នាកណ្តាលត្រពាំង គឺរក្សាទុកសម្រាប់ធ្វើម្ហូបផ្គត់ផ្គង់នៅពេងបុណ្យ ពោលគឺទាំងសម្រាប់ទទួលភ្ញៀវ និងជាចង្ហាន់ប្រគេនព្រះសង្ឃ។ ទន្ទឹមនឹងនេះដែរ ក្នុងថ្ងៃចាប់ត្រីគេក៏សង្កេតឃើញអ្នកភូមិមួយចំនួនទៀតនៅផ្ទះរៀបចំធ្វើនំបញ្ចុកដែលជាអាហារលេចមុខជាងគេក្នុងពិធីឡើងមាឃនៅភូមិបង្កោងៗ[3] លុះស្អែកឡើងនៃថ្ងៃបន្ទាប់ អ្នកភូមិចាប់ផ្តើមរៀបចំម្ហូបចំណី ចង្ហាន់ព្រះសង្ឃ និងគ្រឿងសក្ការៈ ព្រមទាំងស្រូវរៀងៗខ្លួនយកទៅកាន់សាលាបុណ្យ។ នៅក្នុងបរិវេណសាលាបុណ្យគេតែងរៀបចំឱ្យមានភ្នំខ្សាច់ និងរានទិសទាំង៨។ លុះដល់វេលារសៀល គេដាក់ជង្ហ្វាយបន្តិចបន្តួចនៅខ្ទមអ្នកតាច័ន រួចទើបអាចារ្យចាប់ផ្តើមធ្វើកិច្ចប្រុងពាលី លើកទង់ បួងសួងសុំសេចក្តីសុខ ពូនភ្នំខ្សាច់ ភ្នំស្រូវនៅត្រង់ដើមពោធិ៍ក្បែររានទិមរាជនៃទិសឦសាន (រូបលេខ៦-៩)។






រូបលេខ៦-៩ កិច្ចប្រុងពាលី លើកទង់ ពូនភ្នំខ្សាច់ ភ្នំស្រូវក្នុងរសៀលថ្ងៃសូត្រមន្តឡើងមាឃភូមិបង្កោង

[3] សួង សុខរ៉ូ ២០១៦: ២-៧, ផាន់ សុភីនី និងសហសេវិក ២០២១: ១៨៩

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ចំណែកឯចូលមកដល់វេលាព្រលប់ គេនិមន្តព្រះសង្ឃមកចម្រើនព្រះបរិត្តទៅតាមទំនៀមព្រះពុទ្ធសាសនា។ ប៉ុន្តែក្នុងរាត្រីនេះ ពុំមានកិច្ចសម្តែងធម្មទេសនាដូចពិធីបុណ្យផ្សេងៗឡើយ។ លុះព្រឹកឡើងជាថ្ងៃបញ្ចប់ គេធ្វើពិធីរាប់បាត្រឆ្លងបុណ្យ (រូបលេខ១០)។ ចំណែកឯភ្នំខ្សាច់ និងស្រូវដែលអ្នកភូមិយកមកចូលរួមពូន ហើយបំបួសនោះ ក៏ធ្វើកិច្ចផ្សឹកក្នុងថ្ងៃបញ្ចប់នេះដែរ។ ស្រូវទាំងដែលបានមកទាំងអស់ អ្នកភូមិស្រុះស្រួលគ្នាលក់ភ្លាមៗដើម្បីយកប្រាក់ដោះស្រាយការចំណាយផ្សេងៗ និងរក្សាទុកសន្សំក្នុងភូមិ (រូបលេខ១១)។ ចំណែកឯកិច្ចបញ្ចូលបញ្ញាន់រូបអ្នកតា គឺពុំឃើញមានប្រារព្ធដូចពិធីឡើងមាយនៅទីផ្សេងៗដូចជា នៅមុខប្រាសាទអង្គរវត្ត ភូមិនគរក្រៅ ឬនៅវត្តអធ្វារឡើយ។ សូមរំឭកថា ពិធីឡើងមាយនៅភូមិបង្កោងឆ្នាំនេះ ប្រារព្ធចំថ្ងៃ៣-៥កើត ខែមាឃ តែឆ្នាំមុន (២០២៣) ប្រារព្ធនៅថ្ងៃ១១-១៣កើត ខែមាឃ។




*រូបលេខ១០-១១ កិច្ចរាប់បាត្រ និងផ្សឹកភ្នំខ្សាច់ ភ្នំស្រូវក្នុងថ្ងៃបញ្ចប់ពិធីឡើងមាយនៅភូមិបង្កោង*

KHMER CIVILIZATION

សរុបខ្លីមក ទម្លាប់ចាប់ត្រីនៅត្រពាំងបឹងក្នុងភូមិបង្កោង គឺជាផ្នែកមួយនៃទំនៀមឡើងមាយ ដែលអ្នកស្រុកតែងប្រារព្ធក្រោយប្រមូលផលស្រូវរួចរាល់។ ការចាប់ត្រីក្នុងត្រពាំងបុរាណនេះ គេមើលឃើញថាមានទិដ្ឋភាពដ៏គគ្រឹកគគ្រេងខ្លាំងក្លាជាងតំបន់ណាទាំងអស់ សូម្បីតែក្នុងតំបន់អង្គរដូចគ្នា។ ប៉ុន្តែយ៉ាងណាក្តី ការចាប់ត្រីរួមគ្នាមួយឆ្នាំម្តងសម្រាប់ធ្វើពិធីធំៗក្នុងភូមិបែបនេះ បង្ហាញឱ្យឃើញពីតម្លៃនៃសម្បត្តិរួម និងការសាមគ្គីក្នុងភូមិ ហើយក៏ស្តែងឱ្យឃើញពីបរិស្ថាន និងប្រពៃណីប្រតិបត្តិក្នុងសហគមន៍៕

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ខៀវ ច័ន្ទ

២០១៣-២០១៤, "សម្បត្តិរួមនៃសហគមន៍", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ២៩, ទំ.៣៨-៤៣, Friend of Khmer Culture, ភ្នំពេញ

សួង សុខរ៉ូ

២០១៦, "នំបញ្ចុក", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ១១, ទំ. ២-៧, យសោធរ, ភ្នំពេញ

អាំង ជូលាន

២០១២-២០១៣, "៣កើត មាឃធំ", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ២៨, ទំ.៤៣-៤៨, Friend of Khmer Culture, ភ្នំពេញ

ឆាន់ សុភីនី, សោ ចន្ថា, តូច សុភៈ, ជា សំបូរ, អាន សីម៉ា, និង អ៊ូ គន្ធា

២០២១, "កិច្ចពិធីនៅចុងវដ្តស្រូវ៖ ករណីឡើងមាឃនៅភូមិបង្កោង", *ព្រះនគរ*, លេខ៣, ទំ.១៨៣-១៩៦, អាជ្ញាធរជាតិអប្សរា, សៀមរាប

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត